**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**គម្ពាធិការលទ្ធកម្ម(គ.ល)**

**លេខ** : ០៣៤៤/១៩.....**កប/គល**

ថ្ងៃ ព្រហស្បតិ៍ ខែ ពិសាខ ឆ្នាំ កុរ ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ២០១៩

## សេចក្តីជូនដំណឹង

## ស្តីពី

## ការងារបំពាក់សម្ភារបណ្តុះបណ្តាលបច្ចេកទេសវិទ្យាសាស្ត្រកុំព្យូទ័រ និងអេឡិចត្រូនិក សម្រាប់បន្ទប់ពិសោធន៍ នៅវិទ្យាស្ថានពហុបច្ចេកទេសតេជោសែនស្វាយរៀង ឆ្នាំ២០១៩

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈស្តីពីការងារបំពាក់សម្ភារបណ្តុះបណ្តាលបច្ចេកទេសវិទ្យាសាស្ត្រកុំព្យូទ័រ និងអេឡិចត្រូនិក សម្រាប់បន្ទប់ពិសោធន៍ នៅវិទ្យាស្ថានពហុបច្ចេកទេសតេជោសែនស្វាយរៀង ឆ្នាំ២០១៩។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមានអាសយដ្ឋានអគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១៩ តទៅ រៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ០១២ ៦៣២ ៦៣៦ ) ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃនៅម៉ោង ៩:៣០ នាទី ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ២០១៩។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង ៩:៣០ នាទី ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ២០១៩។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

**រដ្ឋមន្ត្រី**

**និងជាប្រធានគណៈកម្មាធិការលទ្ធកម្ម (គ.ល)**

**ចម្លងជូន ៖**

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

-អង្គភាពប្រឆាំងអំពើពុករលួយ

3